# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

## សេចក្តីសម្រេច

## ស្តីពី

# គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ នៃព្រះរាជាណាចក្រកម្ពុជា





សហការដោយ Cambodia ACTs

ឧបត្ថម្ភដោយ terre des hommes និង OAK Foundation

ខែធ្នូ ឆ្នាំ២០០៧

# មាតិកា

**ទំព័រ**


**ទី១ ៖ មាតិកា** ........ *I-II*

**ទី២ ៖ អារម្ភកថា** ........ *III-IV*

**ទី៣ ៖ សារលិខិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ........ *V-VI*

**ទី៤ ៖ សេចក្តីសម្រេចស្តីពីគោលការណ៍សម្រាប់ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ** ........ **១-១៦**

**ប្រការ១ ៖** ត្រូវបានដាក់ឱ្យអនុវត្តសេចក្តីសម្រេចស្តីពីគោលការណ៍ការពារ ........ ២

**ប្រការ២ ៖** និយមន័យ ........ ២

១-កុមារ ........ ២

២-ការជួញដូរកុមារ ........ ២

៣-កុមាររងគ្រោះដោយសារការជួញដូរ ........ ២

៤-អ្នកផ្តល់សេវាសុខុមាលភាពសង្គម ........ ៣

**ប្រការ៣ ៖** គោលការណ៍រួម ........ ៣

១-សិទ្ធិរបស់កុមារ ........ ៣

២-ឧត្តមប្រយោជន៍របស់កុមារ ........ ៣

៣-សិទ្ធិរួចចាកផុតពីការរើសអើង ........ ៣

៤-ការគោរពទស្សនៈរបស់កុមារ ........ ៣

៥-សិទ្ធិទទួលព័ត៌មាន ........ ៤

៦-សិទ្ធិក្នុងការរក្សាភាពសម្ងាត់ ........ ៤

៧-គោរពអត្តសញ្ញាណរបស់កុមារជនជាតិភាគតិច វប្បធម៌ ជំនឿ និងសាសនា ........ ៤

៨-ការទទួលខុសត្រូវរបស់ក្រសួង/ស្ថាប័នដែលពាក់ព័ន្ធ ........ ៤

**ប្រការ៤ ៖** ការណែនាំអនុវត្តជាក់ស្តែង ........ ៥

១-ការស្រាវជ្រាវ និងការកំណត់អត្តសញ្ញាណកុមារ ........ ៥

១.១-ការសន្និដ្ឋានលើអាយុ ........ ៥

១.២-វិធានការកំណត់អត្តសញ្ញាណ ........ ៥

២-ទំនាក់ទំនងដំបូង ........ ៦

២.១-វិធានការដំបូង ........ ៦

២.២-ការសម្ភាសន៍ព័ត៌មានសម្ងាត់ជាមួយនឹងកុមារ ........ ៧
២.៣-ការការពារផ្នែកច្បាប់សម្រាប់កុមារ ........ ៨
៣-ប្រព័ន្ធបញ្ជូន កិច្ចសម្របសម្រួល កិច្ចសហការ និងសហប្រតិបត្តិការ ........ ៩
៣.១-យន្តការថ្នាក់តំបន់ ........ ៩
៣.២-យន្តការថ្នាក់ជាតិ ........ ៩
៤-ការថែទាំបណ្ដោះអាសន្ន និងការការពារ ........ ៩
៤.១-កន្លែងសុវត្ថិភាពសម្រាប់កុមារ ........ ៩
៤.២-សេវាគាំទ្រ ........ ១០
៤.៣-ការធ្វើឱ្យស្របច្បាប់នូវការស្នាក់នៅ ........ ១០
៥-ការគ្រប់គ្រងផ្នែកសង្គមកិច្ចសម្រាប់កុមាររងគ្រោះដោយសារការជួញដូរ ........ ១០
៥.១-ការវាយតម្លៃលើបុគ្គល ........ ១០
៥.២-ការកំណត់ដំណោះស្រាយប្រកបដោយនិរន្តរភាព ........ ១១
៥.៣-ការអនុវត្តដំណោះស្រាយប្រកបដោយនិរន្តរភាព ........ ១១
៥.៤-ការត្រួតពិនិត្យតាមដានលើការអនុវត្តនូវដំណោះស្រាយ
ប្រកបដោយនិរន្តរភាព ........ ១២
៦-លទ្ធភាពទទួលបាននូវយុត្តិធម៌ ........ ១២
៦.១-សន្តិសុខ និងកិច្ចការពារជនរងគ្រោះ/សាក្សី ........ ១២
៦.២-នីតិវិធីព្រហ្មទណ្ឌ ........ ១៣
៦.៣-នីតិវិធីរដ្ឋប្បវេណី ........ ១៤
៧-ការថែទាំ និងការការពារដល់អ្នកផ្ដល់សេវាសុខុមាលភាពសង្គម ........ ១៤
៧.១-សំណងជំងឺចិត្ត ........ ១៤
៧.២-ជំនួយផ្នែកច្បាប់ ........ ១៤
៧.៣-ប្រព័ន្ធគាំទ្រ ........ ១៥
៨-ការកសាងសមត្ថភាព ........ ១៥
៨.១-សហគមន៍ ........ ១៥
៨.២-ក្រុមធ្វើការជាមួយនឹងកុមាររងគ្រោះដោយសារការជួញដូរ ........ ១៥
**ប្រការ៥ :** បទប្បញ្ញត្តិដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ........ ១៦
**ប្រការ៦ :** ក្រសួង ស្ថាប័ន ……….. មានភារកិច្ចអនុវត្តសេចក្ដីសម្រេច ........ ១៦

# អារម្ភកថា

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័នលើពិធីសារជ្រើសរើសស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ នៅឆ្នាំ២០០២។

ក្រោមការដឹកនាំរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានជំរុញការលើកកម្ពស់ការអនុវត្តសិទ្ធិជាមូលដ្ឋានទាំង៤របស់កុមារ។ រាជរដ្ឋាភិបាលបានកសាងនូវគោលនយោបាយ ច្បាប់ និងបទដ្ឋានក្រោមច្បាប់ជាច្រើន ដើម្បីធានាដល់ស្ថានភាពរស់នៅរបស់កុមារឱ្យកាន់តែប្រសើរឡើង មានសុខភាពល្អ ទទួលបានការអប់រំរៀនសូត្រ និងការអភិវឌ្ឍ ប្រឆាំងដាច់ខាតអំពើរំលោភបំពាន អំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ អំពើអាសអាភាស ដែលប៉ះពាល់ដល់សិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់កុមារ។ កម្មវិធី និងសកម្មភាពជាច្រើនត្រូវបានអនុវត្តដោយក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីគាំពារដល់កុមារដែលងាយរងគ្រោះ ជាអាទិ៍ កុមារកំព្រា កុមារពិការ និងកុមារក្នុងគ្រួសារក្រីក្រនៅតាមសហគមន៍។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ចេញសេចក្តីសម្រេចលេខ ១០៧ ក.ជ.ក.ក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៧ ស្តីពី **គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ នៃព្រះរាជាណាចក្រកម្ពុជា** គឺជាផ្នែកដ៏សំខាន់មួយនៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ហើយក៏ជាការអនុវត្តជាក់ស្តែងនូវគោលការណ៍អន្តរជាតិ ដែលបានអនុម័តក្នុងសិក្ខាសាលាថ្នាក់តំបន់កាលពីឆ្នាំ២០០៦ នៅទីក្រុងបាងកក ប្រទេសថៃ។ សេចក្តីសម្រេចមានគោលបំណងជំរុញការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ពិធីសារជ្រើសរើសស្តីពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបអាសអាភាសកុមារ និងលិខិតូបករណ៍អន្តរជាតិផ្សេងៗដែលពាក់ព័ន្ធ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន និងដើម្បីការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ។ សេចក្តីសម្រេចនេះមាន៦ប្រការ ដែលចែងអំពីនិយមន័យកុមារ ការជួញដូរកុមារ គោលការណ៍រួម និងការណែនាំអនុវត្តជាក់ស្តែង សម្រាប់ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធអនុវត្ត ដើម្បីជាឧត្តមប្រយោជន៍សម្រាប់កុមារ។

ក្នុងនាមក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់នូវសារលិខិតចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ដែលជាការគាំទ្រ និងលើកទឹកចិត្តយ៉ាងខ្លាំងចំពោះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិ ក្នុងការជំរុញការផ្សព្វផ្សាយ អនុវត្តសេចក្តីសម្រេចនេះ ដើម្បីឧត្តមប្រយោជន៍កុមារកម្ពុជា។

ខ្ញុំសូមកោតសរសើចំពោះក្រុមការងាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តំណាងក្រសួង ស្ថាប័ន អង្គការមិនមែនរដ្ឋាភិបាល អង្គការអន្តរជាតិពាក់ព័ន្ធ ពិសេសអង្គការ Cambodia ACTs ដែលបានចូលរួមយ៉ាងសកម្មក្នុងការរៀបចំសេចក្តីសម្រេចនេះ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរចំពោះអង្គការ TDHNL-OAK Foundation ដែលបានឧបត្ថម្ភគាំទ្រថវិកាសម្រាប់ការកសាងឯកសារ ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ប្តេជ្ញាជំរុញឱ្យការអនុវត្តសេចក្តីសម្រេចនេះ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីជាឧត្តមប្រយោជន៍ដ៏ពិសិដ្ឋ សម្រាប់ការពារសិទ្ធិកុមារគ្រប់រូបដែលរងគ្រោះដោយសារការជួញដូរ នៅកម្ពុជា។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០០៧*

ជ. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ប្រធាន

អ៊ិត សំហេង

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត

## របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

*- សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជ ព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- បងប្អូនជនរួមជាតិជាទីស្នេហា!*

ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអង្គការសហប្រជាជាតិស្តីពី **សិទ្ធិកុមារ** នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២ និងបានផ្តល់សច្ចាប័នលើពិធីសារស្តីពីការលក់កុមារ ពេស្យាចារកុមារ និងរូបភាពអាសអាភាសកុមារ និងពិធីសារប៉ាលេម៉ូ ដើម្បីទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មដល់ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលជាការបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង។

រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកកុមារគឺ ***ជាទំពាំងស្នងឫស្សី*** ជាអនាគតរបស់ប្រទេសជាតិ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានខិតខំធ្វើឱ្យកុមារទទួលបាននូវសេចក្តីថ្លៃថ្នូរ ពុំមានការរំលោភបំពាន ការប្រើហិង្សាលើរូបកាយ ឬស្មារតី តាមវិធីផ្សេងៗដែលធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងការអភិវឌ្ឍន៍របស់កុមារ។ កុមារត្រូវតែរស់នៅប្រកបដោយសុភមង្គលជាមួយក្រុមគ្រួសារ និងសង្គម និងត្រូវតែទទួលបាននូវសេវាគាំទ្រ ដើម្បីចាកផុតពីពលកម្មធ្ងន់ធ្ងរដែលធ្វើឱ្យកុមារពុំបានរៀនសូត្រ និងប៉ះពាល់ដល់សុខភាព ។ ជាងនេះទៅទៀត បញ្ហាកុមារ គឺជាបញ្ហាអាទិភាព ក្នុងកម្មវិធីអភិវឌ្ឍវិស័យសង្គមកិច្ច ។ បញ្ហាកុមារត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយ ផែនការ និងយុទ្ធសាស្ត្រជាតិជាច្រើន។ ទន្ទឹមនេះដែរ ច្បាប់ និងបទដ្ឋានមួយចំនួនក៏ត្រូវបានបង្កើតឡើង ដើម្បីប្រយុទ្ធប្រឆាំងអំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម អំពើអាសអាភាសលើស្ត្រី និងកុមារ។

ទន្ទឹមនេះ ដើម្បីការពារកុមាររងគ្រោះដោយសារការជួញដូរ ទាមទារឱ្យមានការយកចិត្តទុកដាក់ជាពិសេសក្នុងការថែទាំ ស្តារសម្បទា និងសមាហរណកម្មកុមារទៅក្នុងសហគមន៍វិញឱ្យបានល្អ។ ខ្ញុំសូមថ្លែងការកោតសរសើរចំពោះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និងអង្គការពាក់ព័ន្ធដែលបានរៀបចំសេចក្តីសម្រេចស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា ដែល

ចែងពីនិយមន័យកុមារ ការជួញដូរកុមារ អំពីគោលការណ៍រួម និងការណែនាំអនុវត្តជាក់លាក់សម្រាប់ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធអនុវត្ត ដើម្បីជាឧត្តមប្រយោជន៍របស់កុមារ ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងឋានៈជាប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ខ្ញុំសូមគាំទ្រទាំងស្រុងចំពោះសេចក្តីសម្រេចស្តីពីគោលការណ៍ការពារសិទ្ធិកុមាររងគ្រោះ ដោយសារការជួញដូរនៃព្រះរាជាណាចក្រកម្ពុជា ។

ខ្ញុំសូមអំពាវនាវដល់មាតាបិតា អាណាព្យាបាល សូមយកចិត្តទុកដាក់ពិនិត្យតាមដានឱ្យបានដិតដល់រាល់សកម្មភាពរបស់បុត្រធីតាខ្លួន ហើយអប់រំណែនាំជាប្រចាំ ដើម្បីកុំឱ្យពួកគេធ្លាក់ក្នុងអំពើអបាយមុខផ្សេងៗ ដែលងាយដល់ជនទុច្ចរិតអូសទាញប្រើប្រាស់ក្នុងគោលដៅធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ ពលកម្ម និងបម្រើឧក្រិដ្ឋកម្មរបស់គេ ។

ខ្ញុំសូមអំពាវនាវដល់ក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ សង្គមស៊ីវិល ព្រមទាំងបងប្អូនរួមជាតិទាំងអស់ សូមផ្តល់ការគាំទ្រ ព្រមទាំងបន្តសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងការផ្សព្វផ្សាយ និងអនុវត្តន៍សេចក្តីសម្រេចនេះឱ្យទៅជាការជាក់ស្តែង ដើម្បីបុព្វហេតុកុមារកម្ពុជា ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ២០០៧

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
លេខ : ១០៧ ក.ជ.ក.ក

រាជធានីភ្នំពេញ,ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ២០០៧

# សេចក្តីសម្រេច
# ស្តីពី
# គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ
# នៃព្រះរាជាណាចក្រកម្ពុជា

## ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ
- យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានចុះហត្ថលេខានៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងត្រូវបានផ្តល់សច្ចាប័ន នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២
- យោងតាមពិធីសារជ្រើសរើសដកស្រង់ពីអនុសញ្ញាស្តីពីសិទ្ធិកុមារ អំពីការជួញដូរកុមារ ការធ្វើពេស្យាកម្មកុមារ និងការផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ដែលរដ្ឋសភាបានផ្តល់សច្ចាប័ននៅថ្ងៃទី២ ខែមករា ឆ្នាំ២០០២
- យោងតាមពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែល

មានអង្គការចាត់តាំង ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១០៦/០០៤ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៦

- យោងតាមសេចក្តីណែនាំដែលបានស្នើឡើង សម្រាប់ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ។

## សម្រេច

**ប្រការ ១ :** ត្រូវបានដាក់ឱ្យអនុវត្តសេចក្តីសម្រេចស្តីពី គោលការណ៍ការពារសិទ្ធិកុមាររងគ្រោះដោយសារការជួញដូរ នៃព្រះរាជាណាចក្រកម្ពុជា ដែលមានខ្លឹមសារដូចបានចែងក្នុងប្រការបន្តបន្ទាប់ខាងក្រោមនេះ ។

**ប្រការ ២ :** និយមន័យ

**១. កុមារ**

កុមារ គឺជាជនដែលមានអាយុក្រោម ១៨ ឆ្នាំ ។

**២. ការជួញដូរកុមារ**

ក. ការជួញដូរកុមារ គឺជាការជ្រើសរើស ការដឹកជញ្ជូន ការផ្ទេរ ការផ្តល់កន្លែងលាក់ខ្លួន ឬការទទួលយកកុមារតាមមធ្យោបាយបោកបញ្ឆោត លួងលោម បង្ខិតបង្ខំ ការសុំមកចិញ្ចឹម ឬការរៀបអាពាហ៍ពិពាហ៍ជាដើម ក្នុងគោលបំណងដើម្បីធ្វើអាជីវកម្ម ដូចជា ការកេងប្រវ័ញ្ចលើពលកម្មកុមារ ទាសករកុមារ ពេស្យាចារកុមារ ការផលិតនិងផ្សព្វផ្សាយរូបភាពអាសអាភាសកុមារ ការលក់ដូរសរីរៈ និងការចូលរួមរបស់កុមារក្នុងជម្លោះប្រដាប់អាវុធ ។ល ។

ខ. ការយល់ព្រមរបស់កុមារ ឬការយល់ព្រមរបស់ជនដែលគ្រប់គ្រងកុមារចំពោះការជួញដូរ ឬការយល់ព្រមណាមួយផ្សេងទៀតក្នុងសកម្មភាពនៃការជួញដូរនោះ ។ ការយល់ព្រមនេះមិនអាចលើកលែងទោស ឬបន្ធូរបន្ថយទោសដល់ជនប្រព្រឹត្តិបទល្មើសចំពោះការទទួលខុសត្រូវរបស់ជននោះសម្រាប់ការប្រព្រឹត្តិ ឬជំរុញឱ្យមានការប្រព្រឹត្តការជួញដូរកុមារ ។

គ. ការគំរាមកំហែង ការប្រើកម្លាំង ការបង្ខិតបង្ខំដោយទម្រង់ផ្សេងៗ ការចាប់ពង្រត់ ការឆបោក ការបំភ័ន្ត ការរំលោភបំពានដោយអំណាច ឬតួនាទីទៅលើជនដែលងាយរងគ្រោះ ឬការផ្តល់ ឬទទួលជាលុយកាក់ ឬផលកម្រៃផ្សេងៗ ដើម្បីទទួលបានការយល់ព្រមពីជនដែលគ្រប់គ្រងលើកុមារ ។

**៣. កុមាររងគ្រោះដោយសារការជួញដូរ**

កុមាររងគ្រោះដោយសារការជួញដូរ គឺជាកុមារដែលបានជ្រើសរើស ដឹកជញ្ជូន ផ្ទេរ ផ្តល់កន្លែងលាក់ខ្លួន ឬទទួលយកក្នុងគោលបំណងដើម្បីធ្វើអាជីវកម្មនៅក្នុង ឬក្រៅប្រទេស ។

### ៤. អ្នកផ្តល់សេវាសុខុមាលភាពសង្គម

អ្នកផ្តល់សេវាសុខុមាលភាពសង្គម គឺត្រូវរួមបញ្ចូលជនទាំងអស់ដែលចូលរួមនៅក្នុងការផ្តល់សេវា ដោយផ្ទាល់ដល់កុមាររងគ្រោះដោយសារការជួញដូរ ទោះបីជាមកពីស្ថាប័នរដ្ឋ ឬអង្គការមិនមែនរដ្ឋាភិបាលក៏ដោយ ។

## ប្រការ ៣ : គោលការណ៍រួម

### ១. សិទ្ធិរបស់កុមារ

ក. កុមាររងគ្រោះដោយសារការជួញដូរ មានសិទ្ធិទទួលបាននូវការគោរពយ៉ាងពេញលេញ សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួម ដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ខ. កុមាររងគ្រោះដោយសារការជួញដូរមានតម្រូវការពិសេស ដូច្នេះមានសិទ្ធិទទួលបាននូវវិធានការការពារពិសេសផងដែរ ។

### ២. ឧត្តមប្រយោជន៍របស់កុមារ

នៅគ្រប់សកម្មភាពទាំងអស់ដែលទាក់ទងនឹងកុមាររងគ្រោះដោយសារការជួញដូរ ទោះបីជាត្រូវបានអនុវត្តដោយស្ថាប័នសុខុមាលភាពសាធារណៈរបស់រដ្ឋ ឬឯកជន នគរបាល តុលាការ អាជ្ញាធររដ្ឋបាល ឬអង្គការនីតិបញ្ញត្តិក៏ដោយ ក៏ឧត្តមប្រយោជន៍របស់កុមារទាំងនោះ ត្រូវគិតគូរជាចម្បង ។

### ៣. សិទ្ធិរួចចាកផុតពីការរើសអើង

ក. កុមាររងគ្រោះដោយសារការជួញដូរទាំងអស់ ត្រូវទទួលបាននូវការការពារនិងសិទ្ធិដូចៗគ្នា នៅក្នុងប្រទេសដែលជាកន្លែងកំណើត កន្លែងឆ្លងកាត់ ឬកន្លែងគោលដៅ ដោយមិនគិតពីឋានៈ សញ្ជាតិ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា ទស្សនៈនយោបាយ ឬទស្សនៈដទៃទៀត ជនជាតិដើម ឬសង្គម ទ្រព្យសម្បត្តិ ពិការភាព ស្ថានភាពកំណើត ឬស្ថានភាពអ្វីផ្សេងៗទៀតឡើយ ។

ខ. នៅពេលអនុវត្តសេចក្តីសម្រេចនេះ ត្រូវអនុវត្តផងដែរចំពោះកុមារដែលចាប់កំណើត និងកើតពីមាតាដែលរងគ្រោះដោយសារការជួញដូរ ។

### ៤. ការគោរពទស្សនៈរបស់កុមារ

ក. កុមាររងគ្រោះដោយសារការជួញដូរដែលមានសមត្ថភាពបញ្ចេញទស្សនៈ ត្រូវទទួលបានសិទ្ធិបញ្ចេញទស្សនៈដោយសេរីក្នុងគ្រប់បញ្ហាទាំងឡាយដែលប៉ះពាល់ដល់រូបគេ រួមទាំងបញ្ហាដែលទាក់ទងទៅនឹងនីតិវិធីច្បាប់ ការថែទាំជំនួស ការការពារ ព្រមទាំងការកំណត់ និងការអនុវត្តដំណោះស្រាយមួយដែលមានរយៈពេលសមស្រប ។

ខ. ទស្សនៈរបស់កុមាររងគ្រោះដោយសារការជួញដូរត្រូវយកមកពិចារណា ហើយថ្លឹងថ្លែងទៅតាមអាយុ ភាពចាស់ទុំ សមត្ថភាព និងឧត្តមប្រយោជន៍របស់កុមារ ។

## ៥. សិទ្ធិទទួលព័ត៌មាន

ក. កុមាររងគ្រោះដោយសារការជួញដូរ គួរទទួលបានព័ត៌មានអំពីបញ្ហាទាំងអស់ដែលប៉ះពាល់ដល់ពួកគេរួមទាំងកម្មសិទ្ធិសេវាផ្សេងៗ ការជួបជុំគ្រួសារ និង ឬដំណើរការនៃការធ្វើមាតុភូមិនិវត្តន៍ ។

ខ. ព័ត៌មានដែលផ្តល់ឱ្យគួរជាភាសាដែលកុមារអាចយល់បាន ។ គួរផ្តល់អ្នកបកប្រែដែលសមស្របប្រសិនបើចាំបាច់ ។

## ៦. សិទ្ធិក្នុងការរក្សាភាពសម្ងាត់

ក. មិនត្រូវលាតត្រដាងព័ត៌មានអំពីកុមាររងគ្រោះដោយសារការជួញដូរ ដែលអាចធ្វើឱ្យមានគ្រោះថ្នាក់ដល់កុមារ ឬសមាជិកគ្រួសាររបស់គេឡើយ លើកលែងតែតម្រូវដោយច្បាប់ ។

ខ. វិធានការចាំបាច់ទាំងអស់ត្រូវធ្វើឡើងដើម្បីការពារការសម្ងាត់ផ្ទាល់ខ្លួន និងអត្តសញ្ញាណរបស់កុមាររងគ្រោះដោយសារការជួញដូរ ។ ឈ្មោះ អាសយដ្ឋាន ឬព័ត៌មានដទៃទៀត ដែលអាចឈានដល់ការកំណត់បាននូវអត្តសញ្ញាណរបស់កុមាររងគ្រោះដោយសារការជួញដូរ ឬសមាជិកគ្រួសាររបស់គេ មិនគួរលាតត្រដាងដល់សាធារណៈជន ឬបណ្តាញផ្សព្វផ្សាយព័ត៌មានឡើយ ។

គ. ត្រូវមានការអនុញ្ញាតពីកុមារ មុននឹងលាតត្រដាងព័ត៌មានសម្ងាត់របស់កុមាររងគ្រោះដោយសារការជួញដូរ ទៅតាមមធ្យោបាយដែលសមស្របតាមអាយុរបស់កុមារ ។

## ៧. គោរពអត្តសញ្ញាណរបស់កុមារជនជាតិភាគតិច វប្បធម៌ ជំនឿ និងសាសនា

ក. នៅគ្រប់ពេលវេលាទាំងអស់ ត្រូវគោរពអត្តសញ្ញាណរបស់កុមារជនជាតិភាគតិច វប្បធម៌ ជំនឿ និងសាសនារបស់កុមាររងគ្រោះដោយសារការជួញដូរ ។

ខ. បើអាចធ្វើទៅបាន ត្រូវជួយដល់កុមាររងគ្រោះដោយសារការជួញដូរ ឱ្យគេមានលទ្ធភាពគោរពទំនៀមទំលាប់ ជំនឿ សាសនា និងវប្បធម៌របស់ជនជាតិគេ ។

## ៨. ការទទួលខុសត្រូវរបស់ក្រសួង/ស្ថាប័នដែលពាក់ព័ន្ធ

ក. ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ត្រូវចាត់វិធានការជាវិជ្ជមាន ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ ការពារ និងជួយដល់កុមាររងគ្រោះដោយសារការជួញដូរ ។

ខ. ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ត្រូវចាត់វិធានការផ្នែកច្បាប់ តុលាការ រដ្ឋបាល និងវិធានការដទៃទៀតដែលសមស្របដើម្បីការពារ និងជួយកុមាររងគ្រោះដោយសារការជួញដូរ ។

គ. ក្រសួង ស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ ត្រូវទទួលខុសត្រូវចាត់វិធានការជាមុន ដើម្បីការពារជនដែលផ្តល់ការថែទាំ និងជំនួយដល់កុមាររងគ្រោះដោយសារការជួញដូរ ដើម្បីកុំឱ្យមានការសងសឹកពីអ្នកជួញដូរ។ វិធានការទាំងនេះ គួរគ្របដណ្តប់ដល់អ្នកដែលធ្វើការនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិល និងក្រុមជំនឿសាសនាផងដែរ។

**ប្រការ ៤:** ការណែនាំអនុវត្តជាក់ស្តែង

### ១. ការស្រាវជ្រាវ និងការកំណត់អត្តសញ្ញាណកុមារ

#### ១.១ ការសន្និដ្ឋានលើអាយុ

ក. ក្រៅពីឯកសារ ឬសៀវភៅគ្រួសាររបស់ជនរងគ្រោះដោយសារការជួញដូរ អត្តសញ្ញាណប័ណ្ណ សៀវភៅសិក្ខាគារិក ភិនភាគរូបរាង ភាពចាស់ទុំផ្នែកចិត្តសាស្ត្រ ការអះអាង ប័ណ្ណពិនិត្យសុខភាព ឬ ពិនិត្យធ្មេញ ពិនិត្យឆ្អឹង(ម្រាមដៃ) និងពិនិត្យឌីអិនអេ (Deoxyribonucleic Acid) អាចយកមកពិចារណាក្នុងការកំណត់អាយុកុមាររងគ្រោះដោយសារការជួញដូរ។

ឯកសារទទួលស្គាល់តាមផ្លូវច្បាប់ដែលបញ្ជាក់ពីកំណើត ឬអាយុរបស់កុមារ ដែលទទួលបានពីជនដែលដឹងរឿងទាំងនេះ ក៏អាចយកមកពិចារណា និងឯកសារដែលទាក់ទងទៅនឹងការប្រតិបត្តិផ្នែកវប្បធម៌ ឬជំនឿ ដែលបង្ហាញនូវអាយុ ក៏អាចយកមកពិចារណាផងដែរ។

ខ. នៅពេលគ្មានភាពច្បាស់លាស់អំពីអាយុរបស់ជនរងគ្រោះដោយសារការជួញដូរ ហើយមានកត្តាបង្ហាញឱ្យជឿថាជននោះជាកុមារ គប្បីសន្និដ្ឋានថាជននោះជាកុមារ។

គ. ក្នុងអំឡុងពេលរង់ចាំដ៏សមស្របមួយ សម្រាប់ការផ្ទៀងផ្ទាត់អាយុរបស់ជនរងគ្រោះដោយសារការជួញដូរ ជននោះគួរតែត្រូវបានគេចាត់ទុកថាជាកុមារ ហើយគប្បីទទួលបានវិធានការការពារពិសេសទាំងឡាយ ដែលមានចែងនៅក្នុងសេចក្តីសម្រេចនេះ។

#### ១.២ វិធានការកំណត់អត្តសញ្ញាណ

ក. បង្កើតនីតិវិធីសម្រាប់កំណត់អត្តសញ្ញាណរបស់កុមារ រួមមាន ការពង្រឹងនីតិវិធីនៃការចុះបញ្ជីកំណើត ការកត់ត្រា និងការចុះបញ្ជីកុមារដែលបាត់ខ្លួន ឬត្រូវបានគេធ្វើអាជីវកម្ម ព្រមទាំងការបង្កើតបញ្ជីផ្ទៀងផ្ទាត់នូវព័ត៌មានដែលអាចបង្ហាញថា កុមារម្នាក់ៗគឺជាជនរងគ្រោះដោយសារការជួញដូរ។

ខ. ត្រូវបណ្តុះបណ្តាលអំពីនីតិវិធីនៃការកំណត់អត្តសញ្ញាណឱ្យបានឆាប់រហ័ស ដល់ជនដែលមានទំនាក់ទំនងប្រយោល ឬដោយផ្ទាល់ជាមួយនឹងកុមាររងគ្រោះដោយសារការជួញដូរ (ដូចជា បុគ្គលិកកំពង់ផែ ចំណតអាកាសយានដ្ឋាន មន្ត្រីអន្តោប្រវេសន៍ អ្នកត្រួតពិនិត្យព្រំដែន មន្ត្រីអនុវត្តច្បាប់

អ្នកផ្តល់សេវាសង្គម និងថែទាំសុខភាព ជាដើម) ។ ការបណ្តុះបណ្តាលនេះរួមបញ្ចូលទាំងការបណ្តុះបណ្តាល អំពីការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់នូវព័ត៌មានដែលអាចបង្ហាញថា កុមារម្នាក់គឺជាជនរងគ្រោះដោយសារការជួញដូរ និងរបៀបដែលត្រូវចែកឱ្យដាច់រវាងការរងគ្រោះដោយសារការជួញដូរ និងអន្តោប្រវេសន៍ខុសច្បាប់ ។

គ. ស្ថាប័នមានសមត្ថកិច្ច និងអង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រួសារ សហគមន៍ និងសាធារណជនអំពីបញ្ហាជួញដូរមនុស្ស និងបង្កើតឱ្យមាននីតិវិធីសម្រាប់រាយការណ៍ អំពីករណីសង្ស័យ ឬករណីជួញដូរមនុស្សឱ្យបានពិតប្រាកដ ។

ឃ. ត្រូវមានគោលការណ៍ឱ្យបានច្បាស់លាស់ ក្នុងការផ្លាស់ប្តូរ ឬ ចែករំលែកព័ត៌មានរវាងស្ថាប័នរាជរដ្ឋាភិបាលរួមមាន អាជ្ញាធរអនុវត្តច្បាប់ ស្ថាប័នសុខុមាលភាពសង្គម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីសម្រួលដល់ការកំណត់អត្តសញ្ញាណកុមាររងគ្រោះដោយសារការជួញដូរឱ្យបានឆាប់រហ័ស ។

## ២. ទំនាក់ទំនងដំបូង

### ២.១ វិធានការដំបូង

ក. រាល់ការកំណត់កុមារណាមួយជាជនរងគ្រោះដោយសារការជួញដូរជាផ្លូវការនោះ គឺជាភារកិច្ចរបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ប៉ុន្តែនគរបាល ឬទីភ្នាក់ងារដែលរកឃើញជនរងគ្រោះមុនគេ គឺជាអ្នកមានភារកិច្ចកំណត់ជាលើកដំបូងថា តើកុមារនោះជាជនរងគ្រោះដោយសារការជួញដូរមែន ឬក៏មិនមែន។ ទោះជាយ៉ាងណាក៏ដោយ នគរបាល ឬទីភ្នាក់ងារដែលរកឃើញជនរងគ្រោះមុនគេ ត្រូវតែទាក់ទងភ្លាមទៅទីភ្នាក់ងារផ្តល់សេវាសង្គមកិច្ច ឬទាក់ទងទៅក្រុមគ្រួសារ ឪពុកម្តាយ អ្នកអាណាព្យាបាលរបស់កុមាររងគ្រោះដោយសារការជួញដូរ ។

ប្រសិនបើការកំណត់របស់នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ផ្ទុយពីភ្នាក់ងារដែលបានរកឃើញ និងកំណត់មុនគេ នគរបាល ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ត្រូវបញ្ជូនព័ត៌មានទៅទីភ្នាក់ងារនោះវិញ ដើម្បីស្វែងរកព័ត៌មានបន្ថែម។ នៅក្នុងករណីជួញដូរកុមារឆ្លងដែន ព្រះរាជអាជ្ញាត្រូវផ្តល់ព័ត៌មានដល់នគរបាលអន្តោប្រវេសន៍នៃប្រទេសគោលដៅ តាមរយៈស្ថានទូត ឬស្ថានកុងស៊ុលនៃប្រទេសគោលដៅ ឬឆ្លងកាត់ ដើម្បីផ្តល់ការអនុញ្ញាតស្នាក់នៅបណ្តោះអាសន្នដល់កុមាររងគ្រោះ ។

ខ. រាល់ការស៊ើបអង្កេតមិនត្រូវធ្វើឱ្យប៉ះពាល់ដល់សន្តិសុខរបស់កុមាររងគ្រោះ ដូចជា ការមិនឱ្យជនសង្ស័យដឹងពីការស៊ើបអង្កេត ការរក្សាការសម្ងាត់របស់កុមាររងគ្រោះ ជាងនេះទៅទៀតគឺការហាមឃាត់ :

- ការថតរូបភាព ការថតសម្លេង ការផ្សព្វផ្សាយព័ត៌មានដែលធ្វើឱ្យសាធារណជនដឹងអំពីអត្តសញ្ញាណ ឯកសាររបស់កុមាររងគ្រោះ ។
- ផ្សព្វផ្សាយទិន្នន័យ និងសាវតាជាតិ ឬប្រវត្តិរូបរបស់កុមាររងគ្រោះ ។

គ. ជាគោលការណ៍ មន្ត្រីស៊ើបអង្កេត (នគរបាល ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ) ត្រូវទទួលស្គាល់លិខិតកំណើត ប័ណ្ណគ្រួសារ ឬសៀវភៅគ្រួសារដែលជាប្រភពទិន្នន័យ ជីវប្រវត្តិរបស់កុមាររងគ្រោះធ្វើជាភស្តុតាង ។ នៅក្នុងករណីមិនមានលិខិតខាងលើនេះទេ នគរបាល ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ត្រូវតែទទួលស្គាល់លិខិតបញ្ជាក់ពីអាជ្ញាធរមូលដ្ឋាន ដែលកុមាររងគ្រោះរស់នៅចុងក្រោយ ដែលធានាថាពិតជាត្រឹមត្រូវ ។

ឃ. អ្នកស៊ើបអង្កេតត្រូវជួយដល់កុមាររងគ្រោះដោយសារការជួញដូរ ក្នុងការរកមកវិញនូវទ្រព្យសម្បត្តិផ្ទាល់ខ្លួនរបស់គេ ។ ជាងនេះទៅទៀត កុមាររងគ្រោះដោយសារការជួញដូរត្រូវទទួលបានសំណងរដ្ឋប្បវេណីពីជនល្មើសតាមផ្លូវតុលាការ ។

ង. កុមាររងគ្រោះដោយសារការជួញដូរ ឬសង្ស័យថាត្រូវបានគេជួញដូរ ទោះជាយ៉ាងណាក៏ដោយ (ឃើញជាក់ស្តែង ឬតាមការសង្ស័យ) ត្រូវតែយកចេញពីកន្លែងរកឃើញ និងនាំយកទៅកាន់ទីកន្លែងដែលមានបរិយាកាសល្អ និងមានសុវត្ថិភាព រួមទាំងការបញ្ជូនទៅស្ថាប័ន ឬអង្គការដែលផ្តល់សេវាសង្គម ដែលជាអ្នកធ្វើកិច្ចការនេះ ។ កុមារជាជនរងគ្រោះដោយសារការជួញដូរ មិនត្រូវរក្សានៅក្នុងប៉ុស្តិ៍នគរបាលលើសពី៤៨ម៉ោងឡើយ និងហាមដាច់ខាតយកកុមារដាក់ក្នុងមន្ទីរឃុំឃាំង ។

ច. ក្នុងកាលៈទេសៈណាក៏ដោយ មិនត្រូវដាក់កុមាររងគ្រោះដោយសារការជួញដូរនៅក្នុងបន្ទប់តែមួយជាមួយនឹងកុមាររងគ្រោះដោយសារមូលហេតុផ្សេងៗ និងហាមមានទំនាក់ទំនងដោយផ្ទាល់ជាមួយជនដែលសង្ស័យថា ជាអ្នកជួញដូរកុមារ ។

ឆ. ដើម្បីសុវត្ថិភាព និងសន្តិសុខរបស់កុមាររងគ្រោះដោយសារការជួញដូរ នគរបាលត្រូវធ្វើការប៉ាន់ប្រមាណអំពីភាពគ្រោះថ្នាក់ដែលអាចកើតឡើង ហើយចាំបាច់ត្រូវរក្សាការសម្ងាត់ពីទីកន្លែង និងអ្នកផ្តល់សេវានានាដល់កុមាររងគ្រោះ ។

## ២.២ ការសម្ភាសន៍ព័ត៌មានសម្ងាត់ជាមួយនឹងកុមារ

ក. ការសម្ភាសន៍កុមារដើម្បីប្រមូលព័ត៌មាន ភស្តុតាង គប្បីត្រូវមានការណែនាំគ្រប់ទីភ្នាក់ងារទាំងអស់ដែលពាក់ព័ន្ធ ត្រូវមានបទដ្ឋានឯកភាពគ្នាមួយសម្រាប់យន្តការសម្ភាសន៍នោះ ដូចជា : ទីកន្លែងការបង្កើតភាពស្និតស្នាល សួរសំណួរស្រួលៗនិងងាយយល់ ការប្រើពាក្យសំដីទន់ភ្លន់ ហើយត្រូវជៀសវាងការប្រើសម្ភារៈ ឧបករណ៍ដែលធ្វើឱ្យកុមារខ្លាច ជាពិសេសកុំឱ្យឃើញមុខជនល្មើស ។

ខ. កុមារត្រូវទទួលបាននូវការគោរពសិទ្ធិសម្ងាត់ផ្ទាល់ខ្លួនរបស់គេ មុននឹងសម្ភាសន៍ត្រូវមានការយល់ព្រមពីកុមារដោយផ្ទាល់ ឬពីឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកផ្តល់សេវានានាដែលពាក់ព័ន្ធ។

គ. ត្រូវអនុញ្ញាតឱ្យកុមាររងគ្រោះដោយសារការជួញដូរ មានពេលសម្រាកដើម្បីសម្រួលអារម្មណ៍ និងការហាត់នឿយមុនពេលធ្វើការសម្ភាសន៍។

ឃ. គ្រប់ដំណាក់កាលសម្ភាសន៍កុមាររងគ្រោះដោយសារការជួញដូរ អ្នកស៊ើបអង្កេតគប្បីមានភេទដូចគ្នា និងត្រូវមានអ្នកបកប្រែភាសាច្បាស់លាស់។ ទាំងអ្នកធ្វើសម្ភាសន៍ និងអ្នកបកប្រែភាសាត្រូវតែស្លៀកសម្លៀកបំពាក់ស៊ីវិល ហើយត្រូវបណ្តុះបណ្តាលអំពីរបៀបធ្វើសម្ភាសន៍ជាសម្ងាត់ និងចំណេះដឹងអំពីបញ្ហាជួញដូរកុមារដល់អ្នកសម្ភាសន៍។

ង. មុនពេលសម្ភាសន៍ជាមួយនឹងកុមាររងគ្រោះដោយសារការជួញដូរ អ្នកស៊ើបអង្កេតឬមន្ត្រី គួរស៊ើបសួរថាតើមានអ្នកណា ឬទីភ្នាក់ងារណាបានធ្វើសម្ភាសន៍មុនរួចហើយឬនៅ ហើយប្រសិនបើមាន អ្នកស៊ើបអង្កេតឬមន្ត្រី គួរតែស្វែងរកលទ្ធផលពីការសម្ភាសន៍លើកមុននោះ។

ច. ការសម្ភាសន៍គួរធ្វើជាភាសាដែលកុមាររងគ្រោះដោយសារការជួញដូរចេះ។ បើមិនអាចធ្វើដូច្នោះបាន គួរតែរកអ្នកបកប្រែដែលមានសមត្ថភាព។

ឆ. គួរសម្ភាសន៍កុមាររងគ្រោះដោយសារការជួញដូរ ដោយមានវត្តមានរបស់តំណាងអ្នកផ្តល់សេវាផ្នែកសុខុមាលភាពសង្គម ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬជនពេញវ័យដែលមានការទុកចិត្តពីកុមារ។

ជ. ការធ្វើសម្ភាសន៍កុមាររងគ្រោះដោយសារការជួញដូរ គួរស្ថិតក្នុងបរិយាកាសមួយដែលស្ថិតស្ថាលមានលក្ខណៈល្អ និងគួរគោរពជានិច្ចនូវការសម្ងាត់នៃនីតិវិធី ព្រមទាំងរក្សាការសម្ងាត់ផ្ទាល់ខ្លួនរបស់គេ។

ឈ. មុននឹងប្រើប្រាស់ឧបករណ៍ថត រួមមាន កាមេរ៉ាវីឌីអូ ឬប្រដាប់ថតសម្លេង ត្រូវតែទទួលបានការយល់ព្រមពីកុមាររងគ្រោះដោយសារការជួញដូរ និងឪពុកម្តាយ ឬអ្នកអាណាព្យាបាលរបស់គេ អ្នកផ្តល់សេវាសុខុមាលភាពសង្គម ឬជនពេញវ័យដែលមានការទុកចិត្តពីកុមារ។

## ២.៣ ការការពារផ្នែកច្បាប់សម្រាប់កុមារ

ក. កុមាររងគ្រោះដោយសារការជួញដូរ គឺជាជនរងគ្រោះនៃការរំលោភសិទ្ធិមនុស្ស។ កុមារទាំងនេះមិនត្រូវបានគេចាត់ទុកថាជាអ្នកប្រព្រឹត្តិបទល្មើស ឬទទួលរងទណ្ឌកម្ម ឬទទួលរងការគំរាមកំហែងដោយការដាក់ទណ្ឌកម្មឧក្រិដ្ឋសម្រាប់ការប្រព្រឹត្តិបទល្មើស ដែលទាក់ទងនឹងស្ថានភាពរបស់ពួកគេជាកុមាររងគ្រោះដោយសារការជួញដូរឡើយ។

ខ. ក្នុងការសហការជាមួយនឹងអាជ្ញាធរអនុវត្តច្បាប់ ការទទួលបានសេវាសុខុមាលភាព និងសេវាគាំទ្រជាមូលដ្ឋាន មិនគួរពឹងផ្អែកទាំងស្រុងលើបំណងកុមាររងគ្រោះដោយសារការជួញដូរឡើយ ទោះបីជនរងគ្រោះមិនមានឆន្ទៈក្នុងការដាក់ពាក្យបណ្ដឹង ឬសហការជាមួយអជ្ញាធរ ដើម្បីចាត់ការរឿងនេះក៏ដោយ ។

គ. នៅក្នុងករណីដែលជនណាមួយត្រូវចោទប្រកាន់ពីបទជួញដូរកុមារ រួមទាំងឪពុកម្ដាយ ឬអ្នកអាណាព្យាបាលផងដែរ តុលាការអាចដកសិទ្ធិមេបា ឬអាណាព្យាបាលបានទៅតាមនីតិវិធីច្បាប់ ។

ឃ. បើកុមាររងគ្រោះដោយសារការជួញដូរគ្មានទីពឹង ឬជាកុមារកំព្រា ទីភ្នាក់ងារគាំទ្រកុមារត្រូវតែរកជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ(មេធាវី) ដើម្បីការពារកុមារនោះគ្រប់ដំណាក់កាលនៃដំណើរការនីតិវិធីរឿងក្ដីរបស់គេរហូតដល់ចប់ ។

## ៣. ប្រព័ន្ធបញ្ជូន កិច្ចសម្របសម្រួល កិច្ចសហការ និងសហប្រតិបត្តិការ

### ៣.១ យន្តការថ្នាក់តំបន់

ស្ថាប័នមានសមត្ថកិច្ចរបស់រាជរដ្ឋាភិបាលនឹងពង្រឹង ពង្រីកកិច្ចសហប្រតិបត្តិការ កិច្ចសម្របសម្រួល និងសេវាបញ្ជូនក្នុងតំបន់ ដែលពាក់ព័ន្ធនឹងបញ្ហាជួញដូរកុមារ ។

### ៣.២ យន្តការថ្នាក់ជាតិ

ក. ពង្រឹងយន្តការថ្នាក់ជាតិដែលមានស្រាប់ ដើម្បីបញ្ជូន សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយអង្គការដៃគូជាតិ-អន្តរជាតិ និងអង្គការនានាដែលធ្វើការទាក់ទងនឹងការជួញដូរមនុស្ស ។

ខ. បង្កើតមូលដ្ឋានទិន្នន័យជាតិ ដោយផ្តោតលើព័ត៌មានទាំងឡាយស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរកុមារ ព្រមទាំងទិន្នន័យដែលទាក់ទងនឹងឧប្បត្តិហេតុនៃការជួញដូរកុមារ ដែលកើតឡើងនៅក្នុងប្រទេស ឬដែលប៉ះពាល់ដល់ប្រជាជន ។ ការបង្កើតមូលដ្ឋានទិន្នន័យជាតិបែបនេះគួរពិចារណាផងដែរ ពីសិទ្ធិរក្សាការសម្ងាត់ផ្ទាល់ខ្លួន និងការលាក់ការសម្ងាត់របស់កុមាររងគ្រោះដោយសារការជួញដូរ ។

គ. បន្តបណ្តុះបណ្តាល និងពង្រឹងមន្ត្រីដែលធ្វើការពាក់ព័ន្ធនឹងការបញ្ជូន ដើម្បីធានាឱ្យមានការដោះស្រាយឆាប់រហ័ស មានប្រសិទ្ធភាព និងសមស្របចំពោះករណីកុមារ ។

ឃ. រៀបចំឱ្យមានដំណើរទស្សនកិច្ចសិក្សាក្នុងប្រទេសនិងក្នុងតំបន់ ដើម្បីរៀនសូត្រនិងផ្លាស់ប្តូរបទពិសោធន៍ទៅវិញទៅមក ដើម្បីធ្វើឱ្យការបញ្ជូន ការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការមានប្រសិទ្ធភាពខ្ពស់ ។

## ៤. ការថែទាំបណ្តោះអាសន្ន និងការការពារ

### ៤.១ កន្លែងសុវត្ថិភាពសម្រាប់កុមារ

ក. ផ្តល់ជម្រក មណ្ឌលដែលមានសុវត្ថិភាព សន្តិសុខ និងមានលក្ខណៈល្អតាមតម្រូវការជាក់ស្តែងដល់កុមាររងគ្រោះដោយសារការជួញដូរ ។

ខ. ជម្រក មណ្ឌលសម្រាប់កុមាររងគ្រោះដោយសារការជួញដូរ ត្រូវមានបុគ្គលិកគ្រប់គ្រាន់ដែលមានជំនាញ និងមានសមត្ថភាព ។ ត្រូវយកចិត្តទុកដាក់លើបញ្ហាយេនឌ័រ ដើម្បីឱ្យសមស្របទៅតាមតម្រូវការរបស់កុមាររងគ្រោះដោយសារការជួញដូរ ។

គ. ត្រូវមានយន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃទីជម្រក និងសេវាទាំងឡាយ ។

### ៤.២ សេវាគាំទ្រ

ក. ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវបម្រុងទុកនូវថវិកាប្រចាំឆ្នាំ ដើម្បីធានាសន្តិសុខដល់កុមាររងគ្រោះដោយសារការជួញដូរកុំឱ្យមានការគំរាមកំហែង និងការសងសឹកពីអ្នកជួញដូរ ធានាឱ្យមានអាហារ និងកន្លែងស្នាក់នៅ ការទទួលបានសេវាថែទាំសុខភាព និងការគាំទ្រផ្នែកចិត្តសាស្ត្រ ។

ខ. គោលបំណងចម្បងនៃការថែទាំបណ្តោះអាសន្ន គឺស្តារសម្បទាឡើងវិញ ផ្តល់ការប្រឹក្សាយោបល់ សេវាចិត្តសាស្ត្រ ជំនួយផ្នែកច្បាប់ ការអប់រំ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងសេវាគាំទ្រដទៃទៀត ដែលអាចស្របតាមតម្រូវការរបស់កុមាររងគ្រោះដោយសារការជួញដូរ និងគ្រួសាររបស់ពួកគេ ។

### ៤.៣ ការធ្វើឱ្យស្របច្បាប់នូវការស្នាក់នៅ

ក. ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវតាក់តែងច្បាប់ គោលនយោបាយ និងនីតិវិធីដើម្បីធានាថាកុមាររងគ្រោះដោយសារការជួញដូរ ដែលមិនមានសញ្ជាតិកម្ពុជា មិនត្រូវបានចាត់ទុកជាជនអន្តោប្រវេសន៍ខុសច្បាប់ឡើយ ។

ខ. ចំពោះកុមាររងគ្រោះដោយសារការជួញដូរដែលគ្មានឯកសារស្របច្បាប់ ក្រសួង ស្ថាប័នមានសមត្ថកិច្ច គប្បីជួយកុមារដើម្បីធានាឱ្យបានឆាប់រហ័សនូវស្ថានភាពស្របច្បាប់ ដូចជា ការផ្តល់ទិដ្ឋាការបណ្តោះអាសន្នជាដើម ។

គ. ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវធានាថាកុមាររងគ្រោះដោយសារការជួញដូរ មិនត្រូវបង់ថ្លៃ និងចំណាយផ្សេងៗនៅក្នុងដំណើរការនៃការធ្វើឱ្យបានស្ថានភាពស្របច្បាប់ឡើយ ។

## ៥. ការគ្រប់គ្រងផ្នែកសង្គមកិច្ចសម្រាប់កុមាររងគ្រោះដោយសារការជួញដូរ

### ៥.១. ការវាយតម្លៃលើបុគ្គល

ក. កុមារម្នាក់ៗដែលរងគ្រោះដោយសារការជួញដូរ ត្រូវទទួលបានសិទ្ធិវាយតម្លៃលើករណីរបស់ខ្លួនដោយបុគ្គលិកជំនាញសង្គមកិច្ច ដែលផ្តោតលើឧត្តមប្រយោជន៍របស់កុមារ។ ផែនការគ្រប់គ្រងកិច្ចអន្តរាគមន៍ករណីកុមាររងគ្រោះដោយសាការជួញដូរត្រូវបង្កើតឡើងដើម្បីដោះស្រាយឱ្យបានសមស្រប។

ខ. ផែនការគ្រប់គ្រងករណីកុមាររងគ្រោះដោយសារការជួញដូរ ត្រូវរក្សានូវវប្បធម៌ ជំនឿ និងសាសនារបស់កុមារ។

គ. ក្រសួង ស្ថាប័នមានសមត្ថកិច្ច សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីចាត់វិធានការស្វែងរកគ្រួសាររបស់កុមាររងគ្រោះដោយសារការជួញដូរនោះឱ្យបានជួបជុំគ្រួសារវិញ។

ឃ. ការអនុវត្តផែនការគ្រប់គ្រងកិច្ចអន្តរាគមន៍ករណី ត្រូវធ្វើឡើងដោយអ្នកដែលមានជំនាញសេវាសង្គមកិច្ច។

## ៥.២ ការកំណត់ដំណោះស្រាយប្រកបដោយនិរន្តរភាព

ក. ក្រសួង ស្ថាប័នមានសមត្ថកិច្ច សហការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិដែលពាក់ព័ន្ធ ដើម្បីទទួលខុសត្រូវក្នុងការកំណត់ដំណោះស្រាយឱ្យបានសមស្របបំផុត និងប្រកបដោយនិរន្តរភាពសម្រាប់កុមាររងគ្រោះដោយសារការជួញដូរ។

ខ. ក្នុងដំណើរការនៃការកំណត់ដំណោះស្រាយសម្រាប់កុមាររងគ្រោះដោយសារការជួញដូរ ត្រូវយកចិត្តទុកដាក់គិតគូរដល់ សញ្ជាតិ សាវតាគ្រួសារ បរិយាកាសគ្រួសារ ស្ថានភាពផ្សេងៗ ការប្រឈមមុខនឹងការសងសឹកពីអ្នកជួញដូរ និងសមត្ថភាពក្នុងកិច្ចការពារសន្តិសុខដល់កុមាររងគ្រោះដោយសារការជួញដូរ។

គ. ក្នុងអំឡុងពេលដំណើរការនៃការកំណត់ និងអនុវត្តដំណោះស្រាយ ត្រូវចាត់តាំងអ្នកថែទាំកុមារដែលមានសមត្ថភាព និងមានជំនាញ ដើម្បីជាតំណាង និងជួយកុមាររងគ្រោះដោយសារការជួញដូរក្នុងរយៈពេលមួយដែលជាតម្រូវការចាំបាច់ សំដៅការពារផលប្រយោជន៍របស់កុមារ។

ឃ. នៅពេលបញ្ជូនកុមារដែលត្រូវបានជួញដូរត្រឡប់ទៅប្រទេសដើមវិញ មន្ត្រីមានសមត្ថកិច្ចត្រូវគោរពទស្សនៈរបស់កុមារដោយផ្អែកទៅលើអាយុ ភាពចាស់ទុំ និងសមត្ថភាពរបស់កុមារថាតើគេចង់ទៅរស់នៅជួបជុំគ្រួសារ ឬក៏ទទួលយកការស្នាក់នៅក្នុងស្ថាប័នដែលផ្តល់កន្លែងស្នាក់នៅ។

## ៥.៣ ការអនុវត្តដំណោះស្រាយប្រកបដោយនិរន្តរភាព

ក. ត្រូវជំរុញឱ្យមានការថែទាំកុមារនៅតាមគ្រួសារនិងសហគមន៍។ ការផ្ដល់ការថែទាំកុមារនៅតាមស្ថាប័នដែលផ្ដល់កន្លែងស្នាក់នៅបណ្ដោះអាសន្ន នឹងត្រូវធ្វើឡើងតែក្នុងករណីចាំបាច់ជៀសមិនរួចប៉ុណ្ណោះ។

ខ. នៅពេលធ្វើសមាហរណកម្មកុមាររងគ្រោះដោយសារការជួញដូរឱ្យត្រឡប់ទៅសហគមន៍វិញ ត្រូវរៀបចំការថែទាំឱ្យបានសមស្រប។ ឪពុកម្ដាយ ឬអាណាព្យាបាល សាច់ញាតិរបស់កុមារ និងអ្នកផ្ដល់សេវាសុខុមាលភាពសង្គមដែលធ្វើការងារជាមួយកុមារ ត្រូវទទួលខុសត្រូវផ្ដល់ការថែទាំសុខភាព ការគាំទ្រផ្នែកចិត្តសាស្ត្រ សេវាសង្គម ការអប់រំ និងជំនួយដែលជាមធ្យោបាយចិញ្ចឹមជីវិតដល់កុមាររងគ្រោះដោយសារការជួញដូរ និងគ្រួសាររបស់គេ ព្រមទាំងការពារកុមារដែលរងគ្រោះដោយសារការជួញដូរនោះបានជៀសផុតពីការជួញដូរជាថ្មី។

គ. ក្នុងករណីកុមាររងគ្រោះដោយសារការជួញដូរមិនមែនជាសញ្ជាតិកម្ពុជា អជ្ញាធរមានសមត្ថកិច្ចត្រូវខិតខំផ្ដល់ឯកសារធ្វើដំណើរ និងសម្របសម្រួលជាមួយប្រទេសដើម ដើម្បីឱ្យការវិលត្រឡប់របស់កុមាររងគ្រោះដោយសារការជួញដូរនោះ បានទៅប្រទេសដើមវិញប្រកបដោយសុវត្ថិភាព។

ឃ. នៅក្នុងដំណើរការធ្វើមាតុភូមិនិវត្តន៍របស់កុមាររងគ្រោះដោយសារការជួញដូរទៅកាន់ប្រទេសដើម បើសិនជា ក្រសួង ស្ថាប័នទទួលបន្ទុកពុំមានលទ្ធភាពរ៉ាប់រងលើការចំណាយ គប្បីត្រូវស្វែងរកជំនួយឧបត្ថម្ភពីប្រទេសដើមរបស់កុមារ ឬអង្គការអន្តរជាតិនានា ដូចជា អង្គការសហប្រជាជាតិ ឬអង្គការអន្តរជាតិទេសន្តរប្រវេសន៍។

## ៥.៤ ការត្រួតពិនិត្យតាមដានលើការអនុវត្តនូវដំណោះស្រាយប្រកបដោយនិរន្តរភាព

ត្រូវបង្កើតឱ្យមានប្រព័ន្ធ ឬយន្តការត្រួតពិនិត្យនិងតាមដានការអនុវត្តដំណោះស្រាយប្រកបដោយនិរន្តរភាព និងតាមដានកុមាររងគ្រោះដោយសារការជួញដូរ ដើម្បីជៀសវាងកុំឱ្យកុមារទាំងនោះត្រូវបានជួញដូរជាថ្មីវិញ។

# ៦. លទ្ធភាពទទួលបាននូវយុត្តិធម៌

## ៦.១ សន្តិសុខ និងកិច្ចការពារជនរងគ្រោះ/សាក្សី

ក. កុមារដែលជាជនរងគ្រោះដោយសារការជួញដូរ មិនត្រូវទទួលការបង្ខិតបង្ខំឱ្យធ្វើសាក្សី ក្នុងកំឡុងពេលដែលខ្លួនស្ថិតក្នុងស្ថានភាពពុំអាចផ្ដល់ចម្លើយបានឡើយ។

ខ. អាជ្ញាធរមានសមត្ថកិច្ចគប្បីមានការវាយតម្លៃជាមុនទៅលើកុមារ មុននឹងឱ្យកុមារធ្វើការសម្រេចចិត្តធ្វើជាសាក្សីចំពោះមុខច្បាប់។

គ. កុមាររងគ្រោះដោយសារការជួញដូរដែលយល់ព្រមធ្វើជាសាក្សី ត្រូវទទួលបានកិច្ចការពារពិសេសដើម្បីធានាសុវត្ថិភាពរបស់ខ្លួន ក្រុមគ្រួសាររបស់ខ្លួន និងមនុស្សសំខាន់ដទៃទៀតដែលពាក់ព័ន្ធ។

ឃ. ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជំរះ ត្រូវតែគោរពសិទ្ធិរបស់កុមារក្នុងការយកចម្លើយ។ នីតិវិធីទាំងនេះរួមមាន ការផ្តល់ចម្លើយតាមរយៈការសម្ភាសន៍តាមវីដេអូ ការផ្តល់ភស្តុតាងតាមរយៈទូរទស្សន៍ និងមធ្យោបាយជាក់ស្តែងដទៃទៀត ដើម្បីជៀសវាងការបង្ហាញមុខរបស់កុមារនៅក្នុងបន្ទប់សវនាការ និងការប្រឈមមុខជាមួយជនល្មើសនៅពេលកាត់ទោសដែលនាំឱ្យកុមារមានការភ័យខ្លាច។ រាល់ចម្លើយរបស់កុមាររងគ្រោះដោយសារការជួញដូរត្រូវរក្សាទុកជាការសម្ងាត់។

ង. នគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជំរះ និងទីភ្នាក់ងារគាំទ្រជនរងគ្រោះត្រូវផ្តល់ព័ត៌មានដល់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលស្របច្បាប់របស់កុមាររងគ្រោះដោយសារការជួញដូរអំពីព័ត៌មាន និងទីភ្នាក់ងារគាំទ្រ។

ច. នៅក្នុងករណីដែលមានការវាយតម្លៃពីគ្រូពេទ្យជំនាញផ្នែកចិត្តសាស្ត្រថា កុមាររងគ្រោះដោយសារការជួញដូរមានការប៉ះទង្គិចខាងផ្នែកផ្លូវចិត្ត ឬលើភាពចងចាំរបស់គេ អាជ្ញាធរមានសមត្ថកិច្ចត្រូវតែអនុញ្ញាតឱ្យមានវត្តមានទីប្រឹក្សាផ្នែកចិត្តសាស្ត្រ ឬទីភ្នាក់ងារគាំទ្រកុមាររងគ្រោះនៅក្នុងដំណើរការសម្ភាសន៍យកព័ត៌មាន ភស្តុតាងពីកុមាររងគ្រោះដោយសារការជួញដូរ។

ឆ. អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់របស់កុមារផងដែរ ហើយការបើកសវនាការ គឺជាលក្ខណៈពិសេស ប្រសិនបើមានការស្នើសុំឱ្យមានការបើកសវនាការជាសម្ងាត់ពីភាគីជនរងគ្រោះ។

ជ. នៅគ្រប់ដំណាក់កាលនៃការស៊ើបអង្កេត និងការបើកសវនាការអំពីបទល្មើស សិទ្ធិរក្សាការសម្ងាត់ផ្ទាល់ខ្លួនរបស់កុមាររងគ្រោះត្រូវតែការពារ។ ការសម្ងាត់ខាងលើគប្បីបានធានាដោយអាជ្ញាធរអនុវត្តច្បាប់ ព្រមទាំងអ្នកផ្តល់សេវានានា។

ឈ. ប្រព័ន្ធផ្សព្វផ្សាយត្រូវតែរក្សាការសម្ងាត់ផ្ទាល់ខ្លួនរបស់កុមារ និងការសម្ងាត់នៅគ្រប់នីតិវិធីច្បាប់។

## ៦.២ នីតិវិធីព្រហ្មទណ្ឌ

ក. មុនពេលសម្រេចថា តើត្រូវសហការនៅក្នុងនីតិវិធីបែបនេះឬមិនសហការ កុមាររងគ្រោះដោយសារការជួញដូរត្រូវទទួលបានព័ត៌មានពេញលេញជាភាសាមួយដែលគេយល់បាន អំពីការប្រឈមមុខនឹងគ្រោះថ្នាក់ និងបញ្ហាសន្តិសុខដែលទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ។

ខ. នៅគ្រប់ដំណាក់កាលនៃបណ្តឹងព្រហ្មទណ្ឌ កុមាររងគ្រោះដោយសារការជួញដូរគួរទទួលបាននូវមេធាវីដែលមានសមត្ថភាពគ្រប់គ្រាន់ និងការការពារក្តីដោយឥតគិតថ្លៃ។

គ. សេចក្តីថ្លែងការណ៍របស់អាជ្ញាធរអនុវត្តច្បាប់ មេធាវី ព្រះរាជអាជ្ញា ឬមន្ត្រីចាត់តាំងណាម្នាក់មិនត្រូវរារាំង ឬពន្យារពេលការវិលត្រឡប់ ឬការជួបជុំគ្រួសាររបស់គេវិញឡើយ។

ឃ. ដើម្បីឧត្តមប្រយោជន៍របស់កុមាររងគ្រោះដោយសារការជួញដូរ ការផ្តល់ភស្តុតាង ឬការអះអាងរបស់គេគួរតែត្រូវផ្តល់ និងយកឱ្យឆាប់តាមដែលអាចធ្វើទៅបាន។

ង. ព្រះរាជអាជ្ញា និងតុលាការនឹងរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជួញដូរ ដើម្បីដាក់ចូលជាទ្រព្យសម្បត្តិរដ្ឋ ឬក៏លក់ទ្រព្យសម្បត្តិទាំងនោះសម្រាប់សងបំណុល ឬជំងឺចិត្ត ឬការខូចខាតឱ្យដល់កុមាររងគ្រោះ នៅពេលមានបណ្តឹងទាមទារសំណងការខូចខាត ដែលកើតចេញពីបទល្មើសនៃការជួញដូរនោះ។

### ៦.៣ នីតិវិធីរដ្ឋប្បវេណី

ក. មានតែកុមាររងគ្រោះដោយសារការជួញដូរ ឬឪពុកម្តាយ អ្នកអាណាព្យាបាលរបស់កុមារនោះទេ ដែលមានសិទ្ធិក្នុងការទាមទារសំណងសម្រាប់ការខូចខាត និងជំងឺចិត្តដោយការជួញដូរ។

ខ. ការធ្វើបណ្តឹងអាជ្ញា និងការជំរុញបណ្តឹងអាជ្ញានៃការជួញដូរ គឺជាមុខងាររបស់អយ្យការអមតុលាការខេត្ត-ក្រុង ទោះបីជាកុមាររងគ្រោះដោយការជួញដូរមិនបានប្តឹងក៏ដោយ ឱ្យតែមានបទល្មើសកើតឡើង ហើយត្រូវបានរាយការណ៍ដោយជនអណាមិក ឬក៏មន្ត្រីមានសមត្ថកិច្ច។

គ. កុមាររងគ្រោះដោយសារការជួញដូរ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកតំណាងកុមារអាចដាក់ពាក្យប្តឹងជាមួយការចោទប្រកាន់របស់ព្រះរាជអាជ្ញា ដើម្បីទាមទារការខូចខាត និងជំងឺចិត្ត។ តុលាការត្រូវចាត់មេធាវីដើម្បីការពារដល់កុមារ។

## ៧. ការថែទាំ និងការការពារដល់អ្នកផ្តល់សេវាសុខុមាលភាពសង្គម

### ៧.១ សំណងជំងឺចិត្ត

អ្នកផ្តល់សេវាសុខុមាលភាពសង្គមដែលទទួលរងនូវការឈឺចាប់ ឬរបួសដោយសារការផ្តល់ជំនួយដល់កុមាររងគ្រោះដោយសារការជួញដូរ ជាពិសេសបណ្តាលមកពីការសងសឹកពីអ្នកជួញដូរ មានសិទ្ធិទាមទារសំណងលើការខូចខាត និងជំងឺចិត្តពីអ្នកជួញដូរនោះ។

### ៧.២ ជំនួយផ្នែកច្បាប់

ក្នុងករណីដែលអ្នកជួញដូរដាក់ពាក្យប្តឹងអ្នកផ្តល់សេវាសុខុមាលភាពសង្គម អំពីអំពើណាមួយដែលគេបានធ្វើក្នុងការបំពេញតួនាទីដើម្បីជួយកុមាររងគ្រោះដោយការជួញដូរនោះ តុលាការត្រូវផ្តល់ឱ្យគេនូវការការពារផ្នែកច្បាប់ និងមេធាវីដោយឥតគិតថ្លៃ។

### ៧.៣ ប្រព័ន្ធគាំទ្រ

គួរបង្កើតឱ្យមានប្រព័ន្ធគាំទ្រសម្រាប់អ្នកផ្តល់សេវាសុខុមាលភាពសង្គម និងផ្តល់ទីកន្លែងសម្រាប់ចែករំលែកការរៀនសូត្រ និងបទពិសោធន៍។

## ៨. ការកសាងសមត្ថភាព

### ៨.១ សហគមន៍

សិក្ខាសាលា ប្រជុំ សកម្មភាព និងការបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការយល់ដឹងដល់សហគមន៍ គួរធ្វើដល់កុមារ គ្រួសារ និងសហគមន៍ ដើម្បីឱ្យពួកគេមានលទ្ធភាពចូលរួមយ៉ាងសកម្មក្នុងការការពារកុមារឱ្យជៀសផុតពីការជួញដូរ។

### ៨.២ ក្រុមធ្វើការជាមួយនឹងកុមាររងគ្រោះដោយសារការជួញដូរ

ក. ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធ ត្រូវមានកម្មវិធីបណ្តុះបណ្តាលដល់ជនដែលធ្វើការងារជាមួយនឹងកុមាររងគ្រោះដោយសារការជួញដូរ។ កម្មវិធីនេះគួរផ្អែកលើតម្រូវការរបស់ជនដែលចូលរួមការបណ្តុះបណ្តាល។ ត្រូវមានប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃពីប្រសិទ្ធភាពនៃកម្មវិធីទាំងនេះ។

ខ. ជនដែលធ្វើការងារជាមួយនឹងកុមាររងគ្រោះដោយសារការជួញដូរត្រូវទទួលបានការអប់រំ និងការបណ្តុះបណ្តាល ដែលអាចបង្កើនការយល់ដឹងនិងចំណេះដឹង អំពីបញ្ហាទាក់ទងទៅនឹងការជួញដូរកុមារឱ្យកាន់តែប្រសើរឡើង។ ការបណ្តុះបណ្តាលបែបនេះអាចដាក់បញ្ចូលប្រធានបទស្តីពី សិទ្ធិមនុស្ស សិទ្ធិកុមារ វប្បធម៌ ក្រមសីលធម៌ យេនឌ័រនិងការអភិវឌ្ឍសុខភាពបន្តពូជ ពលកម្មកុមារ បញ្ហាអន្តោប្រវេសន៍ ក្របខណ្ឌច្បាប់ជាតិ-អន្តរជាតិ។

គ. ជនដែលធ្វើការជាមួយកុមាររងគ្រោះដោយសារការជួញដូរត្រូវទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញ ដែលមានប្រយោជន៍ដើម្បីជួយសម្រួលការងាររបស់ពួកគេ។ ការបណ្តុះបណ្តាលនេះ គួរដាក់បញ្ចូលប្រធានបទស្តីពីការផ្តល់ប្រឹក្សាផ្នែកចិត្តសាស្ត្រ និងផ្នែកច្បាប់ ការគ្រប់គ្រង ករណីសង្គម ការចងក្រងឯកសារ ការប្រមូលទិន្នន័យ វិធីសាស្ត្រប្រាស្រ័យទាក់ទង វិធីសាស្ត្រសម្ភាសន៍កុមារមេត្រី សុវត្ថិភាពផ្ទាល់ខ្លួន និងការការពារចំពោះអ្នកផ្តល់សេវាសុខុមាលភាពសង្គម បច្ចេកទេសស៊ើបអង្កេត វិធីដោះស្រាយវិវាទ និងការគ្រប់គ្រងភាពតានតឹងផ្នែកអារម្មណ៍។

ឃ. ក្រសួង ស្ថាប័ន និងអង្គការពាក់ព័ន្ធត្រូវផ្សព្វផ្សាយពីការប្រើប្រាស់សេចក្តីសម្រេចនេះ ដល់ជនដែលធ្វើការជាមួយនឹងកុមាររងគ្រោះដោយសារការជួញដូរឱ្យបានទូលំទូលាយ ។

ង. ក្រសួង ស្ថាប័នជំនាញគួរមានកញ្ចប់ថវិកាសម្រាប់រៀបចំសកម្មភាពកសាងសមត្ថភាព ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៃការបណ្តុះបណ្តាល ដែលបានរៀបរាប់នៅក្នុងសេចក្តីសម្រេចនេះ ។

**ប្រការ ៥៖** បទប្បញ្ញត្តិដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦៖** ក្រសួង ស្ថាប័ន ដែលជាសមាជិក ក.ជ.ក.ក អង្គការជាតិ-អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធនឹងការងារកុមារទាំងអស់ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជ. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

**ប្រធាន**

**អ៊ិត សំហេង**

**ចម្លងជូន** ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ខៀវ ធាញ់**
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ